-រ៉ាប់រងការរក្សា ការទុកដាក់ ឯកសារវិទ្យាសាស្ត្របច្ចេកទេសកសិកម្ម ធានាបាន សុវត្ថិភាព និង សំរបសំរួលធ្វើសេវាកម្មអំពីពត៌មាន ឬ ទិន្នន័យតាមសេចក្តីត្រូវការរបស់អ្នកបច្ចេកទេសកសិកម្មនិង អង្គភាពនានា ។

**មាត្រា ៣** : មជ្ឈមណ្ឌលឯកសារវិទ្យាសាស្ត្របច្ចេកទេសកសិកម្ម ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយរូបជាជំនួយការ ។

**មាត្រា ៤** : មជ្ឈមណ្ឌលឯកសារវិទ្យាសាស្ត្របច្ចេកទេសកសិកម្មរួមមាន ៤ ផ្នែក :

-ផ្នែករក្សាឯកសារ

-ផ្នែកវិភាគទិន្នន័យពត៌មាន

-ផ្នែកគំរោងការ និង សេវាកម្ម

-ផ្នែកប្រមូលលទ្ធផលស្រាវជ្រាវកសិកម្ម និង ភោគផលថ្មី

**មាត្រា ៥** : ក្របខ័ណ្ឌនៃមជ្ឈមណ្ឌលឯកសារវិទ្យាសាស្ត្របច្ចេកទេសកសិកម្ម ត្រូវកំណត់ដោយ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ៦** : អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន ផែនការស្ថិតិប្រធាននាយកដ្ឋាន គណនេយ្យ ហិរញ្ញវត្ថុនិងអង្គភាពពាក់ព័ន្ធនានាត្រូវ ទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ឈា សុខ**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៖

**ប្រកាសលេខ : ៣២៨ ប្រក.កសក.ចត**

**ស្តីពីការបំបែកមូលដ្ឋានជាតិ**

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃអគ្គនាយកដ្ឋានចំការកៅស៊ូ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៣ របស់រាជរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា ស្តីពីការដាក់អគ្គនាយកដ្ឋានចំការកៅស៊ូអោយស្ថិតនៅ ក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមសំណើលេខ ២១២ អន.ចត ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ របស់អគ្គនាយកដ្ឋានចំការកៅស៊ូ ។

**សំរេច**

**មាត្រា ១** : បំបែកមូលដ្ឋានចំការកៅស៊ូមេមត់ដែលមានផ្ទៃដីចំការកៅស៊ូ ៥.២៩៧,៦៤ ហិតា ជាពីរមូលដ្ឋានស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រុមហ៊ុនចំការកៅស៊ូមេមត់ នៃអគ្គនាយកដ្ឋានចំការកៅស៊ូដូចខាងក្រោម :

១-មូលដ្ឋានចំការកៅស៊ូមេមត់មានផ្ទៃដី ២.៨៧៨.៥២ ហិតា នឹងភូមិចំនួន ៤ : ភូមិដូងភូមិខ្នាយ ភូមិស្លា និង ភូមិឡាំបោរ ។

២-មូលដ្ឋានចំការកៅស៊ូកន្ទ្រើយមានផ្ទៃដី ២.៤១៩,១២ ហិតា នឹងភូមិចំនួន ៣ : ភូមិសំបួរ ភូមិក្រូច និង ភូមិក្នុងត្បូង ។

**មាត្រា ២** : ក្រុមហ៊ុនចំការកៅស៊ូមេមត់មានភារកិច្ចរៀបចំចាត់តាំង បែងចែកមន្ត្រីដឹកនាំគ្រប់គ្រងមូលដ្ឋាន ផ្ទៃដីអាជីវកម្ម ព្រំប្រទល់ ភូមិ កំលាំងពលកម្ម ចលនៈទ្រព្យ អចលនៈទ្រព្យ អោយបានសមស្របដូចក្នុងមាត្រា ១ ដើម្បីអោយដំណើរការអនុវត្តន៍ទទួលបានលទ្ធផលល្អប្រសើរ ។

**មាត្រា ៣** : អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានអគ្គនាយកដ្ឋានចំការកៅស៊ូ ប្រធានក្រុមហ៊ុនចំការកៅស៊ូមេមត់ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

**តាវ សេងហួរ**

*　*　*

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ : ៣៣២ ប្រក.កសក**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

*　*　*

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នសរកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ តុលា ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញលិខិតលេខ ៤៦៣ សជណ.កស ចុះថ្ងៃទី ២០ មេសា ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីរាជរដ្ឋាភិបាលបានសំរេចយល់ព្រមជាគោលការណ៍ អោយក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ជួលទីតាំងស្ថានីយ៍ចិញ្ចឹមជ្រូក គីឡូម៉ែត្រលេខ ១១ និង ស្ថានីយ៍ចិញ្ចឹម មាន់ព្រែកសំរោង
- បានឃើញកិច្ចសន្យា ស្តីពីការជួលទីតាំងមជ្ឈមណ្ឌលចិញ្ចឹមជ្រូក គីឡូម៉ែត្រលេខ ១១ រវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រុមហ៊ុន C.P. CAMBODIA Co., Ltd ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦
- បានឃើញកិច្ចសន្យា ស្តីពីការជួលទីតាំងមជ្ឈមណ្ឌលចិញ្ចឹមមាន់ព្រែកសំរោង រវាងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រុមហ៊ុន C.P. CAMBODIA Co., Ltd ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦